**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
**សភាផ្នែករដ្ឋប្បវេណី**
សំណុំរឿង រដ្ឋប្បវេណី
លេខ: ៣៧
ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០០
**សាលដីកា**
លេខ: ១៧៨
ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក ........... ជាចៅក្រម
៤-លោក ............... ជាចៅក្រមជំនួសឲ្យ
លោក ........... ចៅក្រមរបាយការណ៍
៥-លោក .............. ជាចៅក្រម

**ក្រឡាបញ្ជី**

-កញ្ញា .............

**តំណាងមហាអយ្យការ**

-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខសាលដីកា៤៨៨ ចុះថ្ងៃទី២២ខែកក្កដា ឆ្នាំ ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ០៩ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ មស ភេទ ប្រុស អាយុ ៥៣ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើសំណង់ មានទីលំនៅ ផ្ទះលេខ ៦៨៩ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក ក្រុងភ្នំពេញ។ ឪពុកឈ្មោះ ឡាំង សៀន -ស- ម្តាយឈ្មោះ ផន -ស- ប្រពន្ធឈ្មោះ ជំរ សាមិត្ត ។

តំណាងដោយលោក អណ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ សគធ ភេទ ប្រុស អាយុ ៣៥ ឆ្នាំ ជាតិខ្មែរ មុខរបរជាងដែក ទីលំនៅផ្ទះលេខ ៧០៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ កុក គឹមសាន -ស- ម្តាយឈ្មោះ ណាយ -ស- ប្រពន្ធឈ្មោះ ស្រេង សុក ។

**កម្មវត្ថុបណ្តឹង:** ប្តឹងទាមទារប្រាក់ ១០.៣៦៤ ដុល្លារ

បានឃើញបណ្តឹងសាទុក្ខលេខ ៤៤២ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ១៩៩៩ របស់លោក ជា ផេង (ជាមេធាវីទទួលសិទ្ធិ) បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេច នៃសាលដីកាលេខ ៤៨៨ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៧ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០០ របស់តុលាការកំពូល ។

តាមបណ្ដឹងចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ១៩៩៨ របស់ឈ្មោះ សគធ ប្ដឹងទារប្រាក់ពីឈ្មោះ មស ចំនួន ១០.៣៦៤ ដុល្លា ហេតុថា មស ជំពាក់ប្រាក់ខ្លួន ថ្លៃធ្វើជំបូល ទ្វារ បង្អួច ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៥២ "គ" ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ចំពោះមុខគូក្ដី ដែលមានខ្លឹមសារ នៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ១៩៩៨ របស់ដើមចោទឈ្មោះ សគធ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតប្រគល់សិទ្ធិលេខ ១០៨.៩៨៣ រ ចុះថ្ងៃទី១៩ខែមិថុនា ឆ្នាំ ១៩៩៨ ពីលោក មស ឲ្យទៅលោក អណ ទុកជាត្រឹមត្រូវតាមទំម្រង់ និងគតិច្បាប់ ។

៣-ឲ្យលោក មស សងប្រាក់ចំនួន ១០.៣៦៤ ដុល្លាអាមេរិក (មួយម៉ឺន បីរយហុកសិបបួន ) និងជម្ងឺចិត្តចំនួន ២០០០ ដុល្លាអាមេរិក (ពីរពាន់) ទៅឲ្យឈ្មោះ សគធ ។

សំណូមពរជម្ងឺចិត្តលើសពីនេះត្រូវបដិសេធចោល ។ ករណីរឹងទទឹងពុំព្រមសងត្រូវដាក់គុកបង្ខំរូបរាងកាយ និងរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង ដើម្បីជានាសំណងតាមច្បាប់ស្ដីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីគឺ ៖ ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង ១.៨០០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០ រៀល រង្វាន់សាក្សី ២០០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៣០០០ រៀល សរុប ៧០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច ។

-កាលបើហួសបណ្ដឹងឧទ្ធរណ៍ហើយ បង្គាប់ឲ្យលោក មស សងប្រាក់ ៧០០០រៀល ទៅឲ្យដើមចោទវិញ និងឲ្យបង់ពន្ធសមាមាត្រមួយភាគរយ នៃប្រាក់ចំនួន ១២.៣៦៤ ដុល្លាអាមេរិក ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ ភាគរយ និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ ភាគរយ តាមច្បាប់ស្ដីពីប្រាក់ប្រាដាប់ក្ដី ។

៥-សាលក្រមនេះ ជំនុំជំរះជាសាធារណៈចំពោះមុខគូភាគី បើកផ្លូវឧទ្ធរណ៍រយៈពេល ២ ខែ គិតចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៩៨ របស់លោក អណ បានប្ដឹងមិនសុខចិត្តសាលក្រមលេខ ៥២ "ក" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ លើសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៨៨ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ឈ្មោះ អណ ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមលេខ ៥២ (គ) ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការទាំងមូល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០ រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥០០០ រៀល សរុប ១៣.០០០រៀល ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខ ចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៤២ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៩ របស់លោក ជា ផេង (ជាមេធាវីទទួលសិទ្ធិ) បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៤៨៨ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា:

-បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

-សាលដីការដ្ឋប្បវេណីលេខ ៤៨៨ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សគធ ជាដើមចោទ និងជាចុងបណ្តឹសាទុក្ខនាពេលសវនាការ បញ្ជាក់ថា: ដំបូងខ្លួនធ្វើការជាមួយចុងចម្លើយ នៅឆ្នាំ១៩៩៦ ខ្លួនសុំបែកពី សុខ មុំ ហើយឈ្មោះ សុខ មុំ នេះក៏បានធ្វើក្រដាសមួយឲ្យខ្លួនពីការខ្ចីលុយ ឈ្មោះ សុខ មុំ ក៏បានដឹងឮ និងឯកភាពឯការទូទាត់តូបខ្លួនឥតបានដឹងឮទេ ។សូមតុលាការកំពូល ដំកល់សាលដីកាសាលាឧទ្ធរណ៍។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ សគធ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៤២ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៩ របស់លោក ជា ផេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលលោក ជា ផេង ប្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ៤៨៨ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍នោះ គឺជាការខុសឆ្គងពីព្រោះថា ៖

ពុំមានភស្តុតាងណាមួយបញ្ជាក់ថា លោក មស បានស្នើសុំឲ្យលោក ជា ផេង ថណាយក្តី និងបានទទួលការយល់ព្រមពីលោក ជា ផេង ឡើយ ដូច្នេះលោក ជា ផេង ពុំមានគុណសម្បត្តិគ្រប់គ្រាន់អាចប្តឹងសាទុក្ខជំនួសលោក មស ឡើយ តុលាការកំពូលគប្បីលើកពាក្យបណ្តឹង សាទុក្ខរបស់លោក ជា ផេង ចោល ។

-យល់ឃើញថា តុលាការកំពូល បានចេញលិខិតបង្គាប់ឲ្យធ្វើសារណា និងបានកោះហៅលោក មស មកជំនុំជំរះហើយ ប៉ុន្តែលោកពុំបានធ្វើសារណាការពាររឿងក្តីរបស់លោក និងពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខលោក ចាត់ទុកជាចំពោះមុខ ។

## ហេតុដូច្នេះ

-វិនិច្ឆ័យសេចក្តី ចំពោះមុខលោក សគធ កំបាំងមុខលោក មស

ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-លើកបណ្តឹងសាទុក្ខលេខ ៤៤២ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៩ របស់លោក ជា ផេង ចោលជាអសាបង់ ។

២-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៣៧ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០០០ ទៅសាលាឧទ្ធរណ៍ដើម្បីចាត់ការតាមច្បាប់ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០រៀល ដែលលោក សគធ បានបង់ទុកនៅតុលាការកំពូល គឺ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០ រៀល សរុប ១៩.០០០រៀល ហើយតម្រូវឲ្យលោក មស សងប្រាក់ចំនួន ១៩០០០រៀល ទៅលោក សគធ វិញ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៥ខែកញ្ញា ឆ្នាំ២០០០ ។